# គេហដ្ឋានដែលដង្វាយមួយភាគក្នុងដប់ត្រូវបានស្ថាបនាឡើង

ដោយ ចានែល វិលលាម



នេះគឺចាកឃ៍ ។ ទាំងនេះគឺជាប្រាក់កាក់របស់ចាកឃ៍ ដែលលាន់ឮស្នូរក្រឹងៗ ។ នេះគឺជាដង្វាយមួយភាគក្នុងដប់របស់ចាកឃ៍ គឺ ១០ ភាគរយ ។



នេះគឺជាប៊ីស្សពដែលចាប់រលាក់ដៃរបស់ចាកឃ៍ ពេលគាត់បានបង់ដង្វាយមួយភាគក្នុងដប់ គឺ ១០ ភាគរយរបស់គាត់ ។



នេះគឺជាព្យាការី ដែលពេញដោយការរីករាយ និង ដោយការអធិស្ឋាន ដែលបានមានប្រសាសន៍ថា « តោះយើងនាំគ្នាកសាងព្រះវិហារបរិសុទ្ធ » ជាមួយនឹងដង្វាយមួយភាគក្នុងដប់ដែលបានផ្ញើទៅពីប៊ីស្សព ដែលបានចាប់រលាក់ដៃរបស់ចាកយ៍ ពេលគាត់បង់ដង្វាយមួយភាគក្នុងដប់ គឺ ១០ ភាគរយរបស់គាត់ ។



នេះគឺជាព្រះវិហារបរិសុទ្ធ ចែងចាំង និង ស ជាដំណាក់នៃព្រះអម្ចាស់ ដែលពេញដោយពន្លឺ ។

នេះគឺជាដំណាក់ដែលដង្វាយមួយភាគក្នុងដប់បានកសាង ព្រោះព្យាការីបានមានប្រសាសន៍ថា « តោះយើងនាំគ្នាកសាងព្រះវិហារបរិសុទ្ធ » ជាមួយនឹងដង្វាយមួយភាគក្នុងដប់ដែលបានផ្ញើទៅពីប៊ីស្សពដែលបានចាប់រលាក់ដៃរបស់ចាកយ៍ ពេលគាត់បង់ដង្វាយមួយភាគក្នុងដប់ គឺ ១០ ភាគរយរបស់គាត់ ។